**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
Kingdom of Cambodia
Nation Religion King

**ក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
Ministry of Industry & Handicraft
លេខ : [illegible]

រាជធានីភ្នំពេញ, ថ្ងៃទី១៦ ខែ ឧសភា ឆ្នាំ២០១៤

# សេចក្តីជូនដំណឹង

## ស្តីពីការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការឱ្យចូលបម្រើការងារ ក្នុងក្របខ័ណ្ឌក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឆ្នាំ ២០១៤

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម សូមជម្រាបជូនដំណឹងដល់សិស្ស និស្សិត និងសាធារណៈជនឱ្យបានជ្រាបថា៖ ក្រសួងឧស្សាហកម្ម និងសិប្បកម្មនឹងធ្វើការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការចូលបម្រើការងារក្នុងក្របខ័ណ្ឌក្រសួងសម្រាប់ឆ្នាំ ២០១៤នេះ ចំនួន ៥០ កន្លែង ដើម្បីបំពេញការងារនៅតាមទីស្តីការក្រសួង ដូចខាងក្រោម៖

### ១- លក្ខខណ្ឌជ្រើសរើស ៖

១.១. បេក្ខជនទាំងពីរភេទ ដែលមានសញ្ជាតិខ្មែរ ដែលមានអាយុស្របទៅតាមការកំណត់ដូចមានចែងខាងក្រោម៖

- ក- ចំពោះបេក្ខជនដែលដាក់ពាក្យស្នើសុំចុះឈ្មោះប្រឡងចូលក្របខ័ណ្ឌប្រភេទ **ក** ត្រូវមានអាយុច្រើនបំផុតត្រឹម ៣០ឆ្នាំ គិតមកដល់ថ្ងៃប្រឡង។
- ខ- ចំពោះបេក្ខជនដែលដាក់ពាក្យស្នើសុំចុះឈ្មោះប្រឡងចូលក្របខ័ណ្ឌប្រភេទ **ខ** ត្រូវមានអាយុច្រើនបំផុតត្រឹម ២៥ឆ្នាំ គិតមកដល់ថ្ងៃប្រឡង។

១.២. បេក្ខជនក្របខ័ណ្ឌប្រភេទ **ក** ត្រូវមានសញ្ញាបត្រទាបបំផុតសមមូលបរិញ្ញាប័ត្រ។ ចំពោះបេក្ខជនក្របខ័ណ្ឌប្រភេទ **ខ** ត្រូវមានសញ្ញាបត្រទាបបំផុតសមមូលមធ្យមសិក្សាប័ត្រភាគទី ២+ ២ ឆ្នាំសិក្សា (បរិញ្ញាបត្ររង) ក្នុងគ្រឹះស្ថានឧត្តមសិក្សា ។ បេក្ខជនទាំងអស់ ត្រូវមានចំណេះដឹងជាបឋមលើជំនាញកុំព្យូទ័រ (Microsoft Word & Excel) ដែលមានវិញ្ញាបនបត្របញ្ជាក់ការសិក្សាត្រឹមត្រូវ។

១.៣. មិនប្រាសចាកសិទ្ធិខាងផ្លូវរដ្ឋប្បវេណី សិទ្ធិពលរដ្ឋ និងសិទ្ធិខាងនយោបាយ។

១.៤. ចំពោះបេក្ខជនជាជនពិការ ដែលមានសមត្ថភាពសមស្របអាចបម្រើការងារបាន និងបេក្ខជនជាស្ត្រីភេទ ត្រូវបានលើកទឹកចិត្ត និងផ្តល់អាទិភាព។

១.៥. ចំពោះបេក្ខជនដែលស្នើសុំចុះឈ្មោះប្រឡង គឺផ្តល់អាទិភាពសម្រាប់បេក្ខជនដែលមានកម្រិតជំនាញបច្ចេកទេសឆ្លើយតបទៅនឹងតម្រូវការចាំបាច់របស់ក្រសួង។

### ២- មុខជំនាញជ្រើសរើស ៖

១.១. ក្របខ័ណ្ឌ **ក** ចំនួន ៤០ កន្លែង លើមុខជំនាញដូចខាងក្រោម៖

| | |
|---|---|
| - គីមីវិទ្យា | ចំនួន ០៤ កន្លែង |
| - ទេពកោសល្យគីមីចំណីអាហារ | ចំនួន ០៥ កន្លែង |
| - បច្ចេកទេសយន្តសាស្ត្រ | ចំនួន ០៤ កន្លែង |
| - សំណង់ស៊ីវិល | ចំនួន ០៤ កន្លែង |

- អគ្គីសនី និងអេឡិចត្រូនិច ចំនួន ០៥ កន្លែង
- ឧស្សាហកម្ម មេកានិច ចំនួន ០៤ កន្លែង
- ព័ត៌មានវិទ្យា ចំនួន ០៤ កន្លែង
- នីតិសាស្ត្រ និងសេដ្ឋកិច្ច ចំនួន ០២ កន្លែង
- គណនេយ្យ និងគ្រប់គ្រង ចំនួន ០៤ កន្លែង
- ភាសាអង់គ្លេស ចំនួន ០៤ កន្លែង

១.២. ក្របខ័ណ្ឌ **ខ** ចំនួន ១០ កន្លែង លើមុខជំនាញដូចខាងក្រោម៖

- រដ្ឋបាលសាធារណៈ ចំនួន ០៤ កន្លែង
- គ្រប់គ្រង ចំនួន ០២ កន្លែង
- ព័ត៌មានវិទ្យា ចំនួន ០៤ កន្លែង

## ៣- កាលបរិច្ឆេទទទួលពាក្យ និងទីកន្លែងទទួលពាក្យសុំប្រឡង ៖

- <u>កាលបរិច្ឆេទទទួលពាក្យ</u> : ចាប់ពីថ្ងៃផ្សាយដំណឹងនេះតទៅ រៀងរាល់ពេលម៉ោងធ្វើការងារ ពេលព្រឹកចាប់ពីម៉ោង ៧:៣០ -១១:៣០នាទី និងពេលរសៀលចាប់ពីម៉ោង ១៤:៣០-១៧:០០ នាទី ។
- <u>កាលបរិច្ឆេទឈប់ទទួលពាក្យ</u> : ថ្ងៃ សុក្រ ទី ២៥ ខែ កក្កដា ឆ្នាំ២០១៤ ត្រឹមវេលាម៉ោង ១៧: ០០នាទី ជាកាលបរិច្ឆេទចុងក្រោយ។
- <u>ទីកន្លែងទំនាក់ទំនង និងទទួលពាក្យ</u> : នៅលេខាធិការដ្ឋាននៃគណៈកម្មការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការរបស់ក្រសួង (នាយកដ្ឋានបុគ្គលិក ) ។

## ៤- សំណុំលិខិតសុំចុះឈ្មោះប្រឡង ៖

១- ពាក្យសុំចុះឈ្មោះប្រឡងមានបិទតែមប្រ៊ិយ៍ ២០០រៀល (មានគំរូស្រាប់) ចំនួន ០១ ច្បាប់
២- ជីវប្រវត្តិសង្ខេបមានបិទរូបថត ( ៤ គុណ ៦ ) (មានគំរូស្រាប់) ចំនួន ០១ ច្បាប់
៣- សលាកបត្រឯកត្តជន (មានគំរូស្រាប់) ចំនួន ០២ ច្បាប់
៤- រូបថតថ្មី ៤ គុណ ៦ (ថតចំពីមុខ) ចំនួន ០២ សន្លឹក
៥- បង្កាន់ដៃទទួលពាក្យ (មានគំរូស្រាប់) ចំនួន ០២ ច្បាប់
៦- កិច្ចសន្យា (មានគំរូស្រាប់) ចំនួន ០១ ច្បាប់
៧- ច្បាប់ចម្លងប័ណ្ណគ្រួសារ ឬសៀវភៅស្នាក់នៅ ឬអត្តសញ្ញាណប័ណ្ណ ចំនួន ០១ ច្បាប់
៨- លិខិតថ្កោលទោស ( ក្រោយពេលប្រឡងជាប់ ) ចំនួន ០១ ច្បាប់
៩- លិខិតពិនិត្យសុខភាព ( ក្រោយពេលប្រឡងជាប់ ) ចំនួន ០១ ច្បាប់

## ៥- វិញ្ញាសាប្រឡង ៖

*សម្រាប់ការប្រឡងចូលប្រភេទក្របខ័ណ្ឌ « **ខ** »*

១- វិញ្ញាសាវប្បធម៌ទូទៅ *រយៈពេល ២ ម៉ោង*
២- វិញ្ញាសាភាសាអង់គ្លេស *រយៈពេល ១ ម៉ោង និង ៣០ នាទី*

*សម្រាប់ការប្រឡងចូលប្រភេទក្របខ័ណ្ឌ « **គ** »*

១- វិញ្ញាសាវប្បធម៌ទូទៅ *រយៈពេល ២ ម៉ោង*
២- វិញ្ញាសាភាសាអង់គ្លេស *រយៈពេល ១ ម៉ោង និង ៣០ នាទី*
៣- វិញ្ញាសាជំនាញបច្ចេកទេស ដែលទាក់ទងនឹងមុខជំនាញដែលបេក្ខជនស្នើសុំចុះឈ្មោះប្រឡង ដូចបានបញ្ជាក់ខាងលើ *រយៈពេល ២ ម៉ោង*

## ៦- កាលបរិច្ឆេទ និងមណ្ឌលប្រឡង ៖

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម នឹងជូនដំណឹងពេលក្រោយឲ្យបានមុនរយៈពេល ០៣ ថ្ងៃ នៃកាលបរិច្ឆេទប្រឡង សូម បេក្ខជន តាមដានព័ត៌មាននៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម ។

**សេចក្តីបញ្ជាក់៖**

- បេក្ខជន ត្រូវសរសេរ និងបំពេញសំណុំលិខិតសុំចុះឈ្មោះប្រឡង ត្រូវមកដាក់ពាក្យសុំចុះឈ្មោះប្រឡងប្រជែងចូលបម្រើការងារដោយខ្លួនឯងផ្ទាល់
- បេក្ខជន ត្រូវទៅធ្វើលិខិតបញ្ជាក់ពីសុខភាពនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងលិខិតថ្កោលទោសនៅក្រសួងយុត្តិធម៌ ជាបន្ទាន់ក្រោយពីការប្រឡងជាប់
- ករណីរកឃើញអ្នកប្រឡងជំនួស បេក្ខជននឹងត្រូវលុបឈ្មោះចេញពីក្របខ័ណ្ឌក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ អ្នកមកប្រឡងជំនួស នឹងត្រូវទទួលទោសតាមច្បាប់ជាធរមាន។
- ព័ត៌មានលម្អិត សូមមកទំនាក់ទំនងនៅនាយកដ្ឋានបុគ្គលិក ការិយាល័យបៀវត្សរ៍ រៀងរាល់ម៉ោងធ្វើការ។

អាស្រ័យហេតុនេះ សូមសិស្ស-និស្សិត និងសាធារណៈជនទាំងអស់មេត្តាជ្រាបជាព័ត៌មាន។

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
**រដ្ឋលេខាធិការ**

**គឹម ឱម**

កន្លែងទទួល ៖
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- គ្រប់ក្រសួង-ស្ថាប័ន "ដើម្បីជូនជ្រាប"
- គ្រប់អង្គភាពចំណុះក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- គ្រប់គ្រឹះស្ថានសិក្សា
  "ដើម្បីជួយផ្សព្វផ្សាយ"
- ឯកសារ-កាលប្បវត្តិ